ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងរដ្ឋប្បវេណីលេខ ៥០៥
ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១
សាលក្រមលេខ ០០២ ស.រ.ណ/២២
ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២

# គាទនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកណ្ដាល

បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ ២០២២ ដោយមានសមាសភាពចូលរួម៖

## ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

**ដើមចោទឈ្មោះ** [redacted] សុខ ភេទប្រុស អាយុ ៣២ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្ននៅ[redacted] មានលោកមេធាវី [redacted] លោកស្រីមេធាវី [redacted] និង លោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិ និង មានលោកស្រី [redacted] ជាអ្នកបកប្រែសញ្ញា ។

**ចុងចម្លើយឈ្មោះ** [redacted] ស៊ាងលីន ភេទស្រី អាយុ ២៦ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្ននៅ[redacted] មានលោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិ ។

**ខ្លឹមសារសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ**

១. សុំលែងលះរវាងដើមចោទឈ្មោះ [redacted] សុខ និង ចុងចម្លើយឈ្មោះ [redacted] ស៊ាងលីន ។
២. សុំសិទ្ធិគ្រប់គ្រង និង សុំអំណាចមេបាលើកូនឈ្មោះ [redacted] សេង ភេទប្រុស អាយុ ០៩ឆ្នាំ និង ឈ្មោះ [redacted] លី ភេទប្រុស អាយុ ០៧ឆ្នាំ ។
៣. សុំបែងចែកទ្រព្យរួមមាន៖
- ខ្សែក និង ខ្សែដៃ ដែលមានតម្លៃ ១.១២៤ ដុល្លារអាមេរិក
- ខ្សែក និង បន្តោងដែលមានតម្លៃ ១.៣០០.០០០ រៀល
- ខ្សែដៃកថា ដែលមានតម្លៃ ៧៩៥ ដុល្លារអាមេរិក

**ខ្លឹមសារសាលក្រមដែលចុងចម្លើយទាមទារឱ្យតុលាការចេញ (បណ្ដឹងតប)**

១. ឱ្យចុងចម្លើយឈ្មោះ [redacted] ស៊ាងលីន និង ដើមចោទឈ្មោះ [redacted] សុខ លែងលះគ្នា ។

២. សុំសិទ្ធិគ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សាលើកូនឈ្មោះ [redacted] សេង ភេទប្រុស កើតថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៣ និង កូនឈ្មោះ [redacted] លី ភេទប្រុស កើតថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៥ ។

៣. មិនទាមទារអាហារកាតព្វកិច្ចចិញ្ចឹមកូននោះទេ ។

៤. សុំបែងចែកទ្រព្យសម្បត្តិរួម លុយចំនួន ៧០.០០០ (ប្រាំពីរម៉ឺន) ដុល្លារអាមេរិក ។

## អង្គហេតុ និង ចំណុចវិវាទ

### ១. ពន្យល់ត្រួសៗអំពីរឿងក្តី

ដើមចោទបានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយឈ្មោះ [redacted] ស៊ាងលីន ក្នុងអំឡុងឆ្នាំ២០១២ និង បានចុះសំបុត្រអាពាហ៍ពិពាហ៍នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ ព្រមទាំងមានកូនចំនួន ០២នាក់ កូនទី១ ឈ្មោះ [redacted] សេង ភេទប្រុស កើតថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៣ និង កូនទី២ ឈ្មោះ [redacted] លី ភេទប្រុស កើតថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៥ ។ ក្រោយពីរៀបការរួច ដើមចោទ និង ចុងចម្លើយ បានរស់នៅជាមួយឪពុកម្តាយរបស់ដើមចោទនៅភូមិតាខ្មៅ១ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល ប៉ុន្តែចាប់ពីអំឡុងដើមឆ្នាំ២០២១ មក ចុងចម្លើយបានផ្លាស់ប្តូរអត្តចរិត និង អាកប្បកិរិយាទាំងស្រុង ពោលគឺធ្វើអត្តចរិត និង អាកប្បកិរិយាដូចមិនមែនជាប្តីប្រពន្ធ ដោយមិនដែលដេកនៅជាមួយដើមចោទឡើយ ។ ពេលដើមចោទចូលផ្ទះ ឬចេញពីផ្ទះ ចុងចម្លើយតែងតែទ្រគោះបោះបោករបស់របរក្នុងផ្ទះ និង ប្រើពាក្យសម្តីគំរោះគំរើយ និង ជេរប្រមាថដើមចោទ មិនតែប៉ុណ្ណោះចុងចម្លើយថែមទាំងប្រមាថម៉ាក់ងាយមិនគោរពឪពុកម្តាយដើមចោទសោះ ។ ប៉ុន្តែដោយមានការណែនាំ និង សម្រុះសម្រួលពីឪពុកម្តាយ ពូមីង និង អាណិតកូន ដើមចោទស៊ូទ្រាំរស់នៅទាំងឈឺចាប់ក្នុងខណៈដែលចុងចម្លើយមិនពេញចិត្តរស់នៅជាមួយដើមចោទក្នុងបំណងជាប្តីប្រពន្ធតាមច្បាប់ ។

### ២. ចំណុចវិវាទៈ

- តើមានមូលហេតុលែងលះស្របតាមក្រមរដ្ឋប្បវេណីដែរឬទេ ?
- តើភាគីខាងដើមចោទ ឬ ចុងចម្លើយ ដែលគប្បីមានអំណាចមេបាលើកូនជាអនីតិជនទើបមានផលប្រយោជន៍ដល់កូនជាអនីតិជន ?
- តើទ្រព្យមាន ខ្សែក និង ខ្សែដៃ ដែលមានតម្លៃ ១.១២៤ ដុល្លារអាមេរិក ខ្សែកបន្តោង មានតម្លៃ ១.៣០០.០០០ រៀល ខ្សែដៃកថា មានតម្លៃ ៧៩៥ ដុល្លារអាមេរិក ជាទ្រព្យរួម ឬទ្រព្យដោយឡែក ?
- តើប្រាក់ចំនួន ៧០.០០០ ដុល្លារអាមេរិក ដែលភាគីចុងចម្លើយប្តឹងតបលើកឡើង ជាទ្រព្យរួម ឬទ្រព្យដោយឡែក ?

### ៣. ការអះអាងរបស់ដើមចោទ និង សេចក្តីថ្លែងការណ៍របស់អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ

លោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យដើមចោទ បានធ្វើសេចក្តីថ្លែងការណ៍ថាៈ សុំរក្សាខ្លឹមសារដូចក្នុងពាក្យបណ្តឹង ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២១ ។ មេធាវីរបស់ដើមចោទបានធ្វើសេចក្តីថ្លែងការណ៍បន្ថែមទៀតថា សុំឱ្យកូនក្តីខ្ញុំបាទលែងលះជាមួយចុងចម្លើយ ដោយហេតុថាដើមចោទ និង ចុងចម្លើយរស់នៅជាមួយគ្នាតែងតែមានភាពរកាំរកូសមិនចុះសម្រុងនឹងគ្នាដែលនាំឱ្យអស់មនោសញ្ចេតនា ។ ចំពោះសិទ្ធិ

អំណាចមេបាលើកូនដែលកូនក្តីខ្ញុំទាមទារនោះ គឺព្រោះតែកូនក្តីខ្ញុំមានមុខរបរត្រឹមត្រូវ និង ជាក់ស្តែងកូនជាអនីតិជនទាំងពីរនាក់រស់នៅជាមួយកូនក្តីរបស់ខ្ញុំបាទ ។ ចំណែកឯទ្រព្យសម្បត្តិរួមដូចមាននៅត្រង់ចំណុចទី៣ នៃខ្លឹមសារសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ កូនក្តីខ្ញុំបាទមិនទាមទារពីចុងចម្លើយទៀតទេ ។

ដើមចោទឈ្មោះ [redacted] សុខ បានធ្វើសេចក្តីថ្លែងការណ៍បញ្ជាក់បន្ថែមថា ខ្ញុំទទួលស្គាល់សេចក្តីថ្លែងការណ៍របស់មេធាវី ។ ខ្ញុំមិនអាចជានាគ្នាទេ ដោយខ្ញុំអស់មនោសញ្ចេតនាហើយ ។

**៤. ការអះអាងរបស់ចុងចម្លើយ និង សេចក្តីថ្លែងការណ៍របស់អ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយ**

លោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយ បានធ្វើសេចក្តីថ្លែងការណ៍ថា៖ សុំរក្សាខ្លឹមសារដូចក្នុងពាក្យបណ្តឹងតប ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១ ។ មេធាវីរបស់ចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍បន្ថែមទៀតថា ចុងចម្លើយឯកភាពលែងលះដើមចោទ ។ ចុងចម្លើយសុំសិទ្ធិអំណាចមេបាលើកូន ព្រោះកូនក្តីខ្ញុំបាទមានមុខរបរត្រឹមត្រូវ និង មិនទាមទារអាហារកាតព្វកិច្ច ។ សុំបែងចែកទ្រព្យសម្បត្តិរួមដែលមានប្រាក់ចំនួន ៧០.០០០ ដុល្លារអាមេរិក ព្រោះខាងដើមចោទបានដកប្រាក់ពីធនាគារចំនួន ៧០.០០០ ដុល្លារអាមេរិក ដើម្បីទុកជាទ្រព្យសម្បត្តិផ្ទាល់ ។ ក្រោយពីរៀបការមកដើមចោទ និង កូនក្តីខ្ញុំបាទបានរកស៊ីជាមួយគ្នា សន្សំបានលុយ ៧០.០០០ ដុល្លារអាមេរិក ព្រមទាំងខ្សែក និងខ្សែដៃទៀតផង ។

ចុងចម្លើយឈ្មោះ [redacted] **ស៊ាងលីន** បានធ្វើសេចក្តីថ្លែងការណ៍ថា ខ្ញុំទទួលស្គាល់សេចក្តីថ្លែងការណ៍របស់មេធាវី ។ នៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១ ដើមចោទបានដកប្រាក់ពីធនាគារយកទៅរក្សាទុកនៅផ្ទះ ហើយចំពោះទ្រព្យរួមនេះខ្ញុំសុំធ្វើការបែងចែក ។

**៥. ភស្តុតាងមានដូចជា**

- សំបុត្រអាពាហ៍ពិពាហ៍លេខ ១១៥ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ សៀវភៅអាពាហ៍ពិពាហ៍លេខ ០៣/២០១៣ រវាងឈ្មោះ [redacted] សុខ និង ឈ្មោះ [redacted] **ស៊ាងលីន** ។ (ថតចម្លង)
- សំបុត្រកំណើតលេខ ២៦៥ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ សៀវភៅកំណើតលេខ ០៥/២០១៣ មានឈ្មោះ [redacted] **សេង** ភេទប្រុស កើតថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៣ ។ (ថតចម្លង)
- សេចក្តីចម្លងសំបុត្រកំណើត ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៥ ចេញពីសំបុត្រកំណើតលេខ ៤២៦ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៥ សៀវភៅកំណើតលេខ ១០/២០១៥ មានឈ្មោះ [redacted] **លី** ភេទប្រុស កើតថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៥ ។ (ថតចម្លង)
- វិក័យប័ត្រវាយតម្លៃទិញគ្រឿងអលង្ការចំនួន ០៣ ។ (ថតចម្លង)
- កិច្ចសន្យាព្រមព្រៀងចែកផ្លូវឈប់ទទួលស្គាល់ជាប្តី/ប្រពន្ធ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២១ ។ (ថតចម្លង)
- ពាក្យបណ្តឹងតប ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១ របស់ចុងចម្លើយឈ្មោះ [redacted] **ស៊ាងលីន** ។ល



Scanned with CamScanner

## សំអាងហេតុ

១. យោងតាមសំបុត្រអាពាហ៍ពិពាហ៍លេខ ១១៥ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ មានសៀវភៅអាពាហ៍ពិពាហ៍លេខ ០៣/២០១៣ អាចបញ្ជាក់បានថា ដើមចោទឈ្មោះ [redacted] **សុខ** និង ចុងចម្លើយឈ្មោះ [redacted] **ស៊ាងលីន** ជាសហព័ទ្ធនឹងគ្នាត្រឹមត្រូវតាមច្បាប់ ។ ប៉ុន្តែក្នុងការរស់នៅជាមួយគ្នារវាងដើមចោទ និង ចុងចម្លើយ តែងតែមានភាពរកាំរកូសមិនចុះសម្រុងគ្នា ដែលនាំឱ្យអស់មនោសញ្ចេតនា និង មិនអាចផ្សះផ្សាបាន ។ ដូចនេះតុលាការ យល់ឃើញថា មានមូលហេតុនៃការលែងលះ ស្របតាមបញ្ញត្តិមាត្រា **៩៧៨** កថាខណ្ឌទី១ ចំណុច **ង** នៃក្រមរដ្ឋប្បវេណី ។

២. ដើមចោទ និង ចុងចម្លើយ បានស្នើសុំសិទ្ធិអំណាចមេបាលើកូនជាអនីតិជនទាំងពីរនាក់ ឈ្មោះ [redacted] **សេង** និង ឈ្មោះ [redacted] **លី** ។ ក្រោយពីបានរៀបអាពាហ៍ពិពាហ៍រួច ដើមចោទ និង ចុងចម្លើយ ព្រមទាំងកូន ០២នាក់ រស់នៅផ្ទះឪពុកម្តាយរបស់ដើមចោទ ហើយបច្ចុប្បន្នកូនជាអនីតិជនកំពុងរស់នៅជាមួយដើមចោទ ។ ដូចនេះ តុលាការគប្បីសម្រេចឱ្យដើមចោទជាអ្នកមានអំណាចមេបាលើកូនជាអនីតិជនទាំង ០២នាក់ ដើម្បីផលប្រយោជន៍របស់កូននោះ ស្របតាមបញ្ញត្តិមាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី ។

៣. ដើមចោទបានលះបង់ការទាមទារចំពោះទ្រព្យរួមត្រង់ចំណុចទី៣ នៃខ្លឹមសារសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ នៅនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ។ ដូចនេះ តុលាការគប្បីមិនពិចារណាចំណុចនេះទេ ហើយគប្បីច្រានចោលការទាមទារនេះ ។

៤. ចុងចម្លើយសុំទាមទារបែងចែកទ្រព្យរួមជាប្រាក់ចំនួន ៧០.០០០ ដុល្លារអាមេរិក ប៉ុន្តែចុងចម្លើយមិនមានភស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជាក់ថាប្រាក់ចំនួន ៧០.០០០ ដុល្លារអាមេរិក នោះនៅសេសសល់នោះទេ ។ ដូចនេះ តុលាការគប្បីច្រានចោលការទាមទារនេះ ។

៥. តុលាការនឹងពិចារណាអំពីបន្ទុកប្រាក់ប្រដាប់ក្តី ស្របតាមបញ្ញត្តិមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## សេចក្តីសម្រេចបញ្ចប់

១. ឱ្យដើមចោទឈ្មោះ [redacted] **សុខ** និង ចុងចម្លើយឈ្មោះ [redacted] **ស៊ាងលីន** លែងលះគ្នា ដែលមានសំបុត្រអាពាហ៍ពិពាហ៍លេខ ១១៥ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ មានសៀវភៅអាពាហ៍ពិពាហ៍លេខ ០៣/២០១៣ ។

២. ឱ្យដើមចោទឈ្មោះ [redacted] **សុខ** ជាអ្នកមានអំណាចមេបាលើកូនជាអនីតិជន ឈ្មោះ [redacted] **សេង** ភេទប្រុស កើតថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៣ និង ឈ្មោះ [redacted] **លី** ភេទប្រុស កើតថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៥ ។

៣. ច្រានចោលការទាមទារចំណុចទី៣ នៃខ្លឹមសារសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ ។/ុ



Scanned with CamScanner

៤. ច្រានចោលការទាមទារចំណុចទី២ ទី៣ និង ទី៤ នៃខ្លឹមសារសាលក្រមដែលចុងចម្លើយទាមទារឱ្យតុលាការចេញ (បណ្ដឹងតប) ។

៥. បន្ទុកប្រដាប់ក្ដីជារបស់ចុងចម្លើយ ។

សាលក្រមនេះ ប្រកាសនៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២ ។ ភាគីមានសិទ្ធិប្ដឹងឧទ្ធរណ៍នឹងសាលក្រមតាមការកំណត់ច្បាប់ ។

ថ្ងៃពុធ ៨កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
កណ្ដាល, ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២

**ចៅក្រម**

ហត្ថលេខា និង ត្រា [redacted]

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃពុធ ៨កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
កណ្ដាល, ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២

បានឃើញ
**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]